ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ: ១៤១០ ក.អ.ជ


រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោក យ៉ស់ ខូន តំណាងសហគមន៍ជនជាតិដើមភាគតិច ព្រៅ**

**ភូមិកិក្លូង ឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិកិក្លូង ឃុំតាវែងក្រោម ស្រុកតាវែង

**យោង :** - លិខិតចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិកិក្លូង របស់លោក យ៉ស់ ខូន តំណាងសហគមន៍។

- លិខិតលេខ ៣៥៣/១៣ ល.អ.ខ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិកិក្លូង របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិកិក្លូង របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិកិក្លូង ឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី តាមសំណើ ។ សហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិកិក្លូង អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ ស្របតាម គោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងទេសចរណ៍

  "ដើម្បីជូនជ្រាប"
- សាលាខេត្តរតនគិរី
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី

  "ដើម្បីមុខការ"
- ឯកសារ - កាលប្បវត្តិ

ជា សុផារ៉ា